*ឋានសួគ៌ និងឋាននរក (បកប្រែពីភាសាអង់គ្លេស)*

ថ្ងៃមួយ តាបស្សម្នាក់បានជួបព្រះជាម្ចាស់ ហើយគាត់ក៏ពោលទៅកាន់ព្រះអង្គថា "ព្រះអង្គអើយ! សូមទ្រង់ពន្យល់ខ្ញុំម្ចាស់អំពីអត្ថន័យនៃឋានសួគ៌ និងឋាននរកផង" ។

ព្រះជាម្ចាស់បាននាំតាបស្សចូលច្រកមួយមានទ្វារពីរនៅទល់មុខគ្នា។ ព្រះជាម្ចាស់បានបើកទ្វារទីមួយ ហើយប្រាប់តាបស្សឲ្យមើលទៅក្នុងបន្ទប់។ តាបស្សមើលឃើញតុអាហារមូលធំមួយ ហើយមានមនុស្សអង្គុយនៅជុំវិញតុ។ នៅចំកណ្ដាលតុមានស៊ុបមួយឆ្នាំងធំ មានក្លិនឈ្ងុយឆ្ងាញ់យ៉ាងខ្លាំង ធ្វើឲ្យតាបស្សទ្រាំលេបទឹកមាត់មិនបាន ផ្ទុយទៅវិញមនុស្សមានសុខភាពស្គមរីងរៃ និងមើលទៅហាក់ដូចជាអត់អាហារជាយូរមកហើយ។ មនុស្សម្នាក់ៗក្នុងបន្ទប់កំពុងកាន់ស្លាបព្រាមានដងយ៉ាងវែង ហើយអាចដួសស៊ុបក្នុងឆ្នាំងបាន។ ជាអកុសល ដងស្លាបព្រាដ៏វែងធ្វើឲ្យពួកគាត់មិនអាចដាក់ស៊ុបចូលក្នុងមាត់ដោយខ្លួនឯងបានឡើយ។ ឃើញដូចនេះ តាបស្ស មានចិត្តសង្វេគចំពោះទុក្ខវេទនា និងការឈឺចាប់ទាំងនេះជាពន់ពេក។ ពេលនោះព្រះជាម្ចាស់ ក៏មានបន្ទូលថា "នេះហើយគឺជាឋាននរក"។

បន្ទាប់មកពី បានបិទបន្ទប់នេះរួចរាល់ហើយ ព្រះជាម្ចាស់ក៏បានងាកមកបើកទ្វារទីពីរ។ ដូចគ្នានឹងបន្ទប់ទីមួយដែរ បន្ទប់នេះមានស៊ុបដ៏ឈ្ងុយឆ្ងាញ់មួយឆ្នាំងធំស្ថិតនៅចំកណ្ដាលតុមូលដែល មានមនុស្សដែលកំពុងកាន់ស្លាបព្រាដងវែង ប៉ុន្តែមនុស្សក្នុងបន្ទប់នេះមានសុខភាពមាំមួន កំពុងទទួលទានស៊ុបយ៉ាងឆ្ងាញ់ និងជជែកគ្នាយ៉ាងសប្បាយ។ តាបស្សនិយាយថា "ខ្ញុំមិនយល់ពីទិដ្ឋភាពទាំងនេះទេ"។ ព្រះជាម្ចាស់មានបន្ទូលតបវិញថា "នេះជាឋានសួគ៌។ មនុស្សក្នុងបន្ទប់នេះត្រូវការជំនាញយ៉ាងសាមញ្ញមួយគត់។ ដូចបានឃើញផ្ទាល់ភ្នែកហើយ មនុស្សក្នុងបន្ទប់នេះចេះបញ្ចុកស៊ុបគ្នាទៅវិញទៅមក ផ្ទុយពីមនុស្សលោភលន់ គិតតែពីតែផលប្រយោជន៍ផ្ទាល់ខ្លួនដែលមាននៅក្នុងបន្ទប់មុន"។

"ការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនមួយមុខគ្រប់គ្រាន់នាំឲ្យជាតិអន្តរាយហើយ" ៖ www.camldp.org